**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ...០៥...អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការរំសាយក្រុមហ៊ុនសំភារៈកសិកម្មជាសហគ្រាសសាធារណៈ និងក្រុមប្រឹក្សាភិបាល

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី លក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តន៍ព្រះរាជក្រម លក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៣០ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០០៣ ស្តីពីការបង្កើតគណៈកម្មាធិការជាតិអវិនិយោគរបស់រដ្ឋ លើសហគ្រាសចំការកៅស៊ូ ក្រុមហ៊ុនសំភារៈកសិកម្ម និងក្រុមហ៊ុនជលផល
- បានឃើញអនុក្រឹត្យលេខ ១២ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតក្រុមហ៊ុនសំភារៈកសិកម្ម ជាសហគ្រាសសាធារណៈដែលមានលក្ខណៈជាក្រុមហ៊ុនរដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១៨៩ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០០១ របស់រាជរដ្ឋាភិបាល ស្តីពីការតែងតាំងមន្ត្រីត្រួតពិនិត្យរដ្ឋអមក្រុមហ៊ុនសំភារៈកសិកម្ម

- បានឃើញអនុក្រឹត្យលេខ ៣០ អនក្រ.តត ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០០៥ របស់រាជរដ្ឋាភិបាល ស្តីពីការតែងតាំងមន្ត្រីរាជការ
- បានឃើញអនុក្រឹត្យលេខ ៣៩៤ អនក្រ.តត ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០០៥ របស់រាជរដ្ឋាភិបាល ស្តីពីការតែងតាំងក្រុមប្រឹក្សាភិបាលក្រុមហ៊ុនសំភារៈកសិកម្មអាណត្តិទី ២
- លិខិតលេខ ៨៩១ សជណ ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៧ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីសំណើសុំគោលការណ៍រំសាយ លក់ ផ្ទេរទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនសំភារៈកសិកម្ម តាមគោលការណ៍ផ្តល់ប្រាក់សំណងបំរុះបំរូវជូននិយោជិតដែលត្រូវរំសាយ និងការផ្ទេរនិយោជិតចូលមកបំរើការក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- តាមសំណើរបស់គណៈកម្មាធិការជាតិអភិវឌ្ឍន៍សហគ្រាសរបស់រដ្ឋ លើសហគ្រាសចំការកៅស៊ូ ក្រុមហ៊ុនសំភារៈកសិកម្ម និង ក្រុមហ៊ុនជលផល

## ស ម្រេ ច

**មាត្រា ១.-**

រំសាយក្រុមហ៊ុនសំភារៈកសិកម្មជាសហគ្រាសសាធារណៈ ដែលបង្កើតឡើងដោយអនុក្រឹត្យលេខ ១២ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៩ ចាប់ពីថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៧ តទៅ។

**មាត្រា ២.-**

រំសាយក្រុមប្រឹក្សាភិបាល មន្ត្រីត្រួតពិនិត្យរដ្ឋ និង អគ្គនាយកក្រុមហ៊ុនសំភារៈកសិកម្ម ចាប់ពីថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៧ តទៅ។

**មាត្រា ៣.-**

ផ្ទេរលោក ហ៊ាន ប៊ុនធឿរ អគ្គនាយកក្រុមហ៊ុនសំភារៈកសិកម្ម ចូលមកបំរើការងារក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទវិញ ចាប់ពីថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៧ តទៅ។

**មាត្រា ៤.-**

រាល់បំណុលដែលត្រូវទារ និងត្រូវសង រវាងក្រុមហ៊ុនសំភារៈកសិកម្ម និងបណ្តាក្រុមហ៊ុន - ស្ថាប័ននានា - អតិថិជន ប្រគល់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអ្នកដោះស្រាយបន្ត។

**មាត្រា ៥.-**

ក្រុមហ៊ុនសំភារៈកសិកម្ម ត្រូវប្រគល់ត្រាក្រុមហ៊ុន និងឯកសារពាក់ព័ន្ធទាំងឡាយ រួមទាំងឯកសារក្នុងកុំព្យូទ័រ មកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដើម្បីរក្សាទុក។

### មាត្រា ៦.-

ថវិកាដែលនៅសល់ក្នុងគណនី និងបេឡាទាំងអស់របស់ក្រុមហ៊ុនសំភារៈកសិកម្ម ត្រូវបង្វែរចូលថវិកាជាតិ ។ បិទរាល់ គណនីធនាគារទាំងអស់របស់ក្រុមហ៊ុនសំភារៈកសិកម្ម ចាប់ពីថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៧ តទៅ ។

### មាត្រា ៧.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ចាប់ពីថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៧ តទៅ ។

### មាត្រា ៨.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ គណៈកម្មាធិការជាតិអភិវឌ្ឍន៍វិនិយោគ ក្រុមហ៊ុនសំភារៈកសិកម្ម ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ មករា ឆ្នាំ២០០៨

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៨
- ឯកសារ-កាលប្បវត្តិ